# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៣៨
ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩
ជំនុំជម្រះ
លេខ: ៨២៥
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០
សាលក្រម
លេខ: **៥០ "ក"**
ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តតាកែវ នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ១៤ និង ៣០ នាទីរសៀល ដោយមានសមាសភាពដូចតទៅ:

### សមាសភាពជំនុំជម្រះ

លោកជំទាវ [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

### ដើម្បីជំនុំជម្រះ

លើពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ហៅ **គាំង** ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាដក មានទីកន្លែងកំណើត និងមានទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] វុទ្ធ (រស់) ម្ដាយឈ្មោះ [redacted] យ៉ុន (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុន **គ្មាន** ។ **(ឃុំខ្លួនថ្ងៃទី១៩.០៦.២០២៤)**

ជាប់ចោទពីបទ **ប៉ុនប៉ុងឃាតកម្ម** ប្រព្រឹត្តនៅភូមិស្នោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ាប់** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរនាយក វី អាយ ភី មានទីលំនៅបច្ចុប្បន្នភូមិខ្នាទៃ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។



Scanned with CamScanner

-**បានឃើញ**: ដីកាសន្និដ្ឋានស្ថាពរលេខ: ៩០៧ ដ.ស.ព/២០២០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: ដីកាដំណោះស្រាយលេខ: ៤៥៩៧/២០២០ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២៥៩៤ ដកចត/២០២៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: សាលក្រមលេខ: **៣៣ (ឆ)** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ: ៣៧៤/២០២០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: របាយការណ៍លេខ: ២៥/០២៤ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ ។

-**បានឃើញ**: កំណត់ហេតុស្ដីពីការជូនដំណឹងពីសាលក្រមកំបាំងមុខ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ**: សេចក្ដីចម្លងបណ្ដឹងទាស់លេខ: ១១/២០២៤ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ របស់ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ហៅ **គាំង** ។

## អង្គហេតុចោទប្រកាន់

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០២ និង ០០នាទី និងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០១ និង ៤០នាទី នៅចំណុចភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ មានករណី **ប៉ុនប៉ងឃាតកម្ម** បង្កឡើងដោយជនជាប់ចោទ ឈ្មោះ [redacted] **រតនៈត្រៃ** ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ [redacted] **លីហុង** ហៅ **គាំង** ភេទប្រុស អាយុ២៣ឆ្នាំ បានធ្វើសកម្មភាពយកដាវសាំម៉ូរ៉ៃដេញកាប់ភ្ញៀវដែលមកកម្សាន្ត នៅខារ៉ាអូខេក្លឹប ។ ក្នុងពេលធ្វើសកម្មភាពនោះ ធ្វើឱ្យភ្ញៀវរត់គេច ហើយត្រូវបានកម្លាំងសន្តិសុខក៏ជួយអន្តរាគមន៍ ទើបធ្វើឱ្យជនរងគ្រោះបានរួចផុតពីការធ្វើសកម្មភាពរបស់ពិរុទ្ធជនខាងលើ ។

## នាពេលសវនាការ

-ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ហៅ **គាំង មានវត្តមាន** ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ាប់ អវត្តមាន** ។

-សាក្សីឈ្មោះ [redacted] **រតនៈត្រៃ អវត្តមាន** ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] **លីហុង មានវត្តមាន** ។

-ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ហៅ **គាំង** បានឆ្លើយថា: ខ្ញុំបាទចូលមកសាលាដំបូងខេត្តតាកែវ នៅថ្ងៃនេះ ដើម្បីប្ដឹងទាស់ទៅនឹងសាលក្រមលេខ: ៣៣ (ក) ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ដែលបានសម្រេចផ្ដន្ទាទោសខ្ញុំបាទ



Scanned with CamScanner

ដាក់ពន្ធនាគារចំនួន ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន ។ ដែលកន្លងមកខ្ញុំបាទពុំដែលបានទទួលដំណឹងអំពីសាលក្រមដែលសម្រេចផ្តន្ទាទោសលើខ្ញុំបាទទេ ។ ក្នុងរឿងនេះខ្ញុំបាទសុំប្តឹងទាស់ សុំឱ្យតុលាការជំនុំជម្រះឡើងវិញ ។ រឿងដែលចោទប្រកាន់ខ្ញុំបាទប្រហែលអំឡុងឆ្នាំ២០១៩ វេលាម៉ោងប្រាំបួនយប់ ពេលនោះខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ នៅថ្ងៃកើតហេតុខ្ញុំបាទបានចូលក្លឹបជាមួយមិត្តភក្តស្រីខ្ញុំ លុះពេលចេញពីក្លឹបវិញ បានមួយសន្ទុះក្រោយមកស្រាប់តែមានគេមករករឿងគ្នាខ្ញុំបាទក៏បានចូលទៅជួយឃាត់ខ្លាចគេកាប់ទៅលើសន្តិសុខដែលស្គាល់គ្នា លុះស្អែកឡើងខ្ញុំបាទទៅធ្វើការនៅកំពុងសោមហើយរយៈ ពេលពីឆ្នាំទើបខ្ញុំបាទបានមកលេងផ្ទះម្តង ។ នៅថ្ងៃកើតហេតុក្រុមដែលបង្កជំលោះមានគ្នាប្រហែលដប់នាក់ដែលជាគ្នារបស់ឈ្មោះ [redacted] យូន និងជាគ្នារបស់ឈ្មោះ [redacted] រតនៈត្រៃ និងភាគីម្ខាងទៀតមានគ្នាច្រើនតែខ្ញុំបាទពុំបានស្គាល់នោះទេ ។ នៅថ្ងៃកើតហេតុខ្ញុំបាទមិនជាប់ពាក់ព័ន្ធនោះទេ ខ្ញុំបាទមិនស្គាល់ឈ្មោះ [redacted] យូន នោះទេខ្ញុំស្គាល់តែឈ្មោះ [redacted] រតនៈត្រៃ ដែលជាអ្នកធ្លាប់រៀនជាមួយគ្នា ។ ឈ្មោះ [redacted] រតនៈត្រៃ ជាអ្នកកាន់ដាវតែមិនបានកាប់ទៅលើអ្នកណាឱ្យមានរបួសនោះទេ ។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ាប់ បានឆ្លើយថា នៅថ្ងៃកើតហេតុឈ្មោះ [redacted] រតនៈត្រៃ និងឈ្មោះ [redacted] លីហុង ប្រដាប់ដោយដាវសាំម៉ូរ៉ៃ និងម៉ូតូមួយគ្រឿង បានធ្វើសកម្មភាពដេញកាប់និងអុកឡុកជាមួយភ្ញៀវ និងបុគ្គលិកសន្តិសុខរបស់ខ្លួន តែមិនបណ្តាលឱ្យភ្ញៀវរបួសនោះទេ ។ ក្នុងរឿងនេះ ខ្លួនសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] រតនៈត្រៃ បានឆ្លើយថានៅថ្ងៃកើតហេតុខ្លួន និងឈ្មោះ ជា នាំគ្នាជិះម៉ូតូត្រឡប់មកពីហូបបបរសវិញ និងបានចូលទៅក្លឹបវីអាយភី ពេលមកដល់ឃើញគេឈ្លោះគ្នា ពេលនោះដែរ ខ្លួនឃើញឈ្មោះ [redacted] លីហុង ហៅ គាំង បានរត់ចេញពីក្លឹបចេញក្រៅទាញដាវពីក្រុមពួកវាមានគ្នាប្រហែល ១០ នាក់ ប៉ុន្តែខ្លួនមិនបានស្គាល់អ្នកទាំងនោះទេ ។ នៅពេលដែលឈ្មោះ គាំង យកដាវហើយបានរត់ចូលទៅក្នុងក្លឹបដើម្បីកាប់អ្នកឈ្លោះគ្នាជាមួយឈ្មោះ [redacted] យូន ហើយខ្លួនក៏ចូលទៅចាប់ឃាត់ទាញដាវចេញពីឈ្មោះ គាំង ស្រាប់តែឈ្មោះ ណាង មកចាប់ខ្លួនទៅវិញដោយទាញអាវខ្លួនរហែក ខ្លួនខឹងពេកក៏ជិះម៉ូតូចេញទៅ ។ ខ្លួនពុំមានកាន់ដាវចូលទៅរករឿងអ្នកណានោះទេ គឺខ្លួនគ្រាន់តែចូលទៅឃាត់ឈ្មោះ គាំង តែប៉ុណ្ណោះ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ការសួរដេញដោលនៅក្នុងអង្គសវនាការ ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី និងក្រោយពីបានពិនិត្យឯកសារផ្សេងៗ ដែលមានក្នុងសំណុំរឿងរួចមក ឃើញថាពិរុទ្ធជនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរ



Scanned with CamScanner

ប្រាកដមែន ។ ដូចច្នេះតំណាងអយ្យការ ស្នើសុំឱ្យតុលាការតម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ៣៣ (ឆ) ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការដដែល ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] **លីហុង** បានធ្វើសេចក្តីសន្និដ្ឋានការពារដល់កូនក្តីថា ក្រោយពីបានពិភាក្សាដេញដោល ក្រោយពីបានស្តាប់ចម្លើយកូនក្តីខ្ញុំបាទ ក្រោយពីបានស្តាប់អំណាចម្លើយរបស់ដើមរដ្ឋប្បវេណី និង ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីនានា ឃើញថាកូនក្តីខ្ញុំបាទឈ្មោះ [redacted] **លីហុង** ពុំបានប្រព្រឹតបទល្មើសប៉ុនប៉ងឃាតកម្ម ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ។ ដោយកូនក្តីរបស់ខ្ញុំបាទពុំមានចេតនាឆក់យកជីវិតជនរងគ្រោះនោះឡើយ គឺគ្រាន់តែប្រើប្រាស់ហិង្សាតែប៉ុណ្ណោះ ។ ហេតុដូចនេះក្នុងនាម ខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យកូនក្តីខ្ញុំបាទសូមស្នើសុំដល់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចកែប្រែបទចោទប្រកាន់លើកូនក្តីខ្ញុំបាទពីបទ **ប៉ុនប៉ុងឃាតកម្ម** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មកជាបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ឱ្យកូនក្តីខ្ញុំបាទផង ។

-ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** បានសំណូមពរសុំដល់តុលាការ មេត្តាជួយរកយុត្តិធម៌ដល់រូបខ្ញុំបាទផង ដោយសម្រេចឱ្យខ្ញុំបាទបានរួចផុតពីការចោទប្រកាន់ ដោយហេតុថានៅថ្ងៃកើតហេតុខ្ញុំបាទពុំបានប្រព្រឹត្តដូចអង្គហេតុខាងលើនេះនោះទេ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី ។

-ក្រោយពីបានពិនិត្យឯកសារ និង ភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន ។

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ពិរុទ្ធជន ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-បណ្តឹងទាស់របស់ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ២៧ឆ្នាំ គឺធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។ ហេតុដូច្នេះ គប្បីតុលាការលើកយកសំណុំរឿងព្រហ្មទណ្ឌលេខ: ៥៣៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តតាកែវ មកជំនុំជម្រះសារឡើងវិញ ។



Scanned with CamScanner

២-តាមសាលក្រមព្រហ្មទណ្ឌលេខ: ៣៣ (ឆ) ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ពិរុទ្ធជនមានសិទ្ធិប្តឹងទាស់លើសាលក្រម ដែលតុលាការបានសម្រេចសេចក្តីកំបាំងមុខតាមបញ្ញត្តិមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយចំពោះពិរុទ្ធជនឈ្មោះ [redacted] **លីហុង** បានប្តឹងទាស់លើសាលក្រមខាងលើនេះ ដោយបានប្តឹងទាស់គ្រង់សេចក្តីសម្រេចដែលបានផ្តន្ទាទោសដល់ខ្លួន ។ ហេតុដូច្នេះគប្បីតុលាការ ទទួលយកបណ្តឹងទាស់នេះមកជំនុំជម្រះ និងសម្រេចសារជាថ្មីម្តងទៀតបានតាមបញ្ញត្តិមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី ក្រោយពីបានពិនិត្យភស្តុតាងនានា និងតាមអង្គហេតុជាក់ស្តែងរួចមក តុលាការរកពុំឃើញ មានបទល្មើស **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌនោះទេ តែតុលាការរកឃើញ បទល្មើស **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ២៧ឆ្នាំ ។

៤-គ្មានភស្តុតាងណាមួយបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ២៨ឆ្នាំ ជាជនវិកលចរិត ឬ វិបល្លាសស្មារតីឡើយ ផ្ទុយទៅវិញជនជាប់ចោទជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៥-គ្មានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ: **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នោះទេ ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ២៧ឆ្នាំ (អត្តសញ្ញាណខាងលើ) ពីបទ: **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ ។

៧-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសង្គម ។ គប្បីតុលាការពិចារណាក្នុងការដាក់ទណ្ឌកម្មលើជនជាប់ចោទ ។



Scanned with CamScanner

៨-ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ២៨ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណីបានថា នៅក្នុងរឿងនេះ ខ្លួនស្នើសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។ គប្បីតុលាការទទួលយកមកពិចារណាសម្រេចតាមភាពជាក់ស្តែង ។

៩-ការស្នើសុំតម្កល់របស់តំណាងអយ្យការ ក្នុងពេលសវនាការដោយស្នើសុំឱ្យតុលាការ តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ **៣៣ (ឆ)** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការដដែល ។ គប្បីតុលាការពិចារណាសម្រេចតាមអង្គហេតុ និងអង្គច្បាប់ ។

១០-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ភេទប្រុស អាយុ២៧ឆ្នាំ ។ គប្បីតុលាការពិចារណាសម្រេចទៅតាមអង្គហេតុ និងអង្គច្បាប់ ។

១១-ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** បានសំណូមពរសុំដល់តុលាការ មេត្តាជួយរកយុត្តិធម៌ដល់រូបខ្លួនផង ដោយសម្រេចឱ្យខ្លួនបានរួចផុតពីការចោទប្រកាន់ ដោយហេតុថានៅថ្ងៃកើតហេតុខ្លួនពុំបានប្រព្រឹត្តដូចអង្គហេតុខាងលើនេះនោះទេ ។

## ហេតុដូច្នេះសម្រេច

១-ទទួលពាក្យបណ្តឹងទាស់របស់ពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-កែប្រែសាលក្រមព្រហ្មទណ្ឌលេខៈ **៣៣ (ឆ)** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ដែលសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] **លីហុង** ហៅ **តាំង** ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន **១០ (ដប់) ឆ្នាំ** ពីបទៈ **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

៣-កែប្រែបទចោទកាន់លើពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ហៅ **តាំង** ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ

មកជាបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ ។

៤-ផ្តន្ទាទោសលើពិរុទ្ធជនឈ្មោះ [redacted] **លីហុង** ហៅ **តាំង** ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ៤ (បួន) ឆ្នាំ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិស្មោរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] លីហុង និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ាប់ ។

-ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | | | |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ១៤ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
តាកែវ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**
[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]



Scanned with CamScanner